# ប្រកាសលេខ ១៤៧

# ស្តីពីបរិយាកាសកំ

# ដៅក្នុងទីកន្លែង

# ធ្វើការ

ណែនាំនិងឧបត្ថម្ភដោយ

-ឯកឧត្តម ជីវ សុខហាក់

-ឯកឧត្តម ប៊ុន ហុន ចំនួន៨00$

-ឯកឧត្តម កើត រិទ្ធ

-លោក តាន់ សេណារ៉ុង

ឯកសារនេះត្រូវបានការពារ
ដោយច្បាប់នៃព្រះរាជាណា-
ចក្រកម្ពុជាតាមមាត្រា៣និង
មាត្រា១១ នៃច្បាប់ស្តីពីម៉ាក
ពាណិជ្ជនាម និងអំពើនៃការ
ប្រកួតប្រជែងមិនស្មោះត្រង់
ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

www.ekasar.com



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ១៤៧ ស.ក.ប.យ

ភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# បរិយាកាសកំដៅក្នុងទីកន្លែងធ្វើការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ចស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណា ឱ្យបរិយាកាសកំដៅក្នុងទីកន្លែងធ្វើការស្ថិតនៅក្នុងកំរិតដែលអាចទទួលយកបាន ។ បរិយាកាសកំដៅនេះត្រូវឱ្យសមស្របទៅនិងសុខភាពនៃអ្នកធ្វើការ ហើយមិនបង្កឱ្យមានការរំខានដល់ការងាររបស់គេទាំងពួង ។ បរិយាកាសកំដៅនេះត្រូវបានត្រួតពិនិត្យដោយ សីតុណ្ហមាត្រ "តែវស្ទង់កំដៅ" ដែលដាក់នៅទីកន្លែងធ្វើការ ។

www.ekasar.com

ប្រការ២.- អគារ ឬ រោងជាង ត្រូវឱ្យមានមាឌ១០ម៉ែត្រគូបយ៉ាងតិច ក្នុងល័ក្ខខ័ណ្ឌធម្មតាសំរាប់កម្មករនិយោជិតម្នាក់ៗ ។ ទីកន្លែងធ្វើការត្រូវបង្ការឱ្យដាច់ពីកំដៅខ្លាំងនៃពន្លឺព្រះអាទិត្យ ។ របៀបផលិតដែលមិនបញ្ចេញកំដៅ គួរទទួលយកជាឯកសិទ្ធិ ។ ប្រសិនបើការផលិតបញ្ចេញកំដៅខ្លាំង និយោជកត្រូវកាត់បន្ថយកំដៅនោះដោយ ៖

- រុំភ្ជិតឬបង្ខាំងបរិក្ខារការងារដែលបញ្ចេញកំដៅ (ដូចជាប្រពន្ធ័នាំចំហាយជាដើម)
- ស្រូបយកកំដៅនិងបញ្ចៀសកំដៅតាំងពីដើមប្រភព ។

ប្រការ៣.- ក្នុងករណីដែលទីកន្លែងធ្វើការមានកំដៅឡើងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬធ្វើឱ្យទើសទាល់ដល់ការងាររបស់កម្មករនិយោជិត និយោជកត្រូវរកគ្រប់មធ្យោបាយដើម្បីធ្វើឱ្យទីកន្លែងធ្វើការបានត្រជាក់វិញដូចជាដាក់កង្ហារ ម៉ាស៊ីនស្រូបខ្យល់ ឬម៉ាស៊ីនត្រជាក់ជាដើម ។

ប្រការ៤.- កម្មករនិយោជិតដែលធ្វើការនៅទីកន្លែង ដែលមានបរិយាកាសត្រជាក់ខ្លាំង ត្រូវមានសិទ្ធិទទួលបាននូវមធ្យោបាយទប់ទល់និងធាតុត្រជាក់ដូចជា ខោអាវក្រាស់ មួក ស្រោមដៃជាដើម ។

ប្រការ៥.- អ្នកប្រព្រឹត្តល្មើសនិងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៦.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
  "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
  និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ